នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Aug-2016, 15:16
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរួមរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពេលវេលាបន្ថែមដើម្បីសួរដេញដោលអ្នកជំនាញ 2-TCE-81 និង 2-TCE-82**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោក Nicholas KOUMJIAN
លោកស្រី ជា លាង

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## សំណើ

1. នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានប្រាស្រ័យទាក់ទងតាមអ៊ីមែលទៅកាន់ភាគីនានា អំពីបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញចំនួន១២នាក់ ដែលបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យមកផ្តល់សក្ខីកម្ម នៅក្នុងអំឡុងពេលនៃផ្នែកសវនាការនៅក្នុងសំណុំរឿង០០២/០២ ស្តីពីបញ្ញត្តិនៃអាពាហ៍ពិពាហ៍[1]។ បញ្ជីឈ្មោះដែលបានភ្ជាប់មកជាមួយនឹងអ៊ីមែលនោះ មានចែងអំពីលំដាប់លំដោយនៃការចូលខ្លួនដែលបានរំពឹងទុក ក៏ដូចជាពេលវេលាដែលបានបែងចែកសម្រាប់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញនីមួយៗ ដែលត្រូវកោះហៅ។ អ្នកជំនាញពីរនាក់ស្តីពីបញ្ញត្តិនៃអាពាហ៍ពិពាហ៍ នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ (“DK”) គឺ 2-TCE-81 និង 2-TCE-82 ត្រូវបានគេរំពឹងថានឹងផ្តល់សក្ខីកម្មនៅចុងក្រោយនៃផ្នែកនេះ គឺមួយថ្ងៃម្នាក់។ អនុលោមតាមបញ្ជីឈ្មោះដែលបានផ្តល់ដោយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី នឹងត្រូវបានបែងចែកពេលវេលាកន្លះថ្ងៃ ចែករំលែកគ្នា ដើម្បីសួរដេញដោលអ្នកជំនាញនីមួយៗ។

2. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះសាលាដំបូង ឲ្យកែប្រែកាលវិភាគដែលស្នើឡើងនេះ ដោយបែងចែកពេលវេលាសរុបចំនួន ១.៥ ថ្ងៃ សម្រាប់អ្នកជំនាញនីមួយៗ។ សំណើនេះត្រូវបានធ្វើយុត្តិកម្មដោយភាពចាំបាច់ក្នុងការរុករកនូវគោលនយោបាយស្តីពីបញ្ញត្តិនៃអាពាហ៍ពិពាហ៍ដោយបង្ខំឲ្យបានពិស្តារពេញលេញ។ ការស្រាវជ្រាវជាច្រើនត្រូវបានដំណើរការ និងបោះពុម្ពផ្សាយស្តីពីប្រធានបទនេះ ហើយបញ្ហាស្មុគស្មាញ ផ្សេងៗដែលជាប់ទាក់ទង បានប៉ះពាល់ដល់ជនរងគ្រោះរាប់ពាន់នាក់។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បញ្ជាក់ថាការចែករំលែកគ្នាបីវគ្គ ដើម្បីសួរដេញដោលអ្នកជំនាញម្នាក់ៗនេះ នឹងផ្តល់ឱកាសគ្រប់គ្រាន់ឲ្យដល់ 2-TCE-81 និង 2-TCE-82 ក្នុងវិសាលភាពពេញលេញ ចាំបាច់ដើម្បីធានាថា អង្គជំនុំជម្រះសាលាដំបូងមានទស្សនៈ មួយពេញលេញអំពីចំណេះដឹងរបស់អ្នកជំនាញលើប្រធានបទនេះ។

---

[1] អ៊ីមែលពី Kenneth W. Roberts, មន្ត្រីច្បាប់ជាន់ខ្ពស់, ជូនដល់ភាគីនានា, ផ្ញើចេញនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង ១៣:៥១ និងមានចំណងជើងថា “បញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ស្តីពីបញ្ញត្តិនៃអាពាហ៍ពិពាហ៍”។

3. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពិចារណាថា ពួកគាត់ត្រូវការពេលវេលាបន្ថែមសម្រាប់ការបង្ហាញអំពីវិសាលភាពនៃព្យសនកម្មដែលទទួលរងដោយដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងនាមជាជនរងគ្រោះនៃគោលនយោបាយទូទាំងប្រទេស ដែលត្រូវបានចោទអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដោយរបបកម្ពុជាប្រជាធិបតេយ្យនោះ។ មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំពីររយចិតសិបប្រាំបួននាក់ (៧៧៩) ត្រូវបានទទួលយកដាក់ក្នុងសំណុំរឿង០០២ ជាជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមានជនរងគ្រោះចំនួន៤៧៤នាក់ ជាជនរងគ្រោះដោយផ្ទាល់។ ក្រុមនៃដើម្បបណ្ដឹងរដ្ឋប្បវេណីនេះស្ថិតក្នុងចំណោមក្រុមធំបំផុតនៃដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងក្រុមរួម និងបង្ហាញឲ្យឃើញអំពីចំនួនជាច្រើននៃជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់--ជនរងគ្រោះបុរស និងស្ត្រី ដែលមកពីគ្រប់ស្រទាប់សង្គមទាំងអស់ ទាំងខាងក្នុង និងខាងក្រៅបក្សកុម្មុយនីសកម្ពុជា និងដែលត្រូវបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងភូមិភាគនីមួយៗរបស់កម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ចំនួនពេលវេលាសមស្របមួយគួរត្រូវបានផ្ដល់ជូនសម្រាប់ប្រធានបទនេះ ដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃបានត្រឹមត្រូវលើព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងនៅពេលព្រឹត្តិការណ៍នោះ ក៏ដូចជាផលវិបាកយូរអង្វែងនានាចំពោះជនរងគ្រោះ និងសង្គមកម្ពុជាជាទូទៅ។ ការពិភាក្សាពេញលេញមួយនៃព្យសនកម្មមានសារៈសំខាន់ក្នុងការបង្ហាញថាតើបញ្ញត្តិស្ដីពីអាពាហ៍ពិពាហ៍ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យស្ថិតក្នុងស្ថានទម្ងន់ និងភាពធ្ងន់ធ្ងរដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ឬទេ។

4. ដោយសារសហព្រះរាជអាជ្ញាមានបន្ទុកភស្តុតាង ហើយនេះជាពេលដំបូងដែលគោលនយោបាយនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះសាលាដំបូងនោះ សហព្រះរាជអាជ្ញាត្រូវការពេលវេលាបន្ថែម ក្នុងចំណោមប្រធានបទផ្សេងទៀត ដើម្បីស្វែងរកថាតើយោបល់របស់អ្នកជំនាញទាក់ទងយ៉ាងដូចម្ដេច ទៅនឹងភស្តុតាងផ្សេងទៀតនៅចំពោះមុខអង្គជំនុំជម្រះ។

5. អាស្រ័យហេតុផលទាំងអស់នេះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបែងចែកវគ្គសវនាការចំនួនប្រាំមួយពេល (មួយថ្ងៃកន្លះ) ដើម្បីស្ដាប់អ្នកជំនាញនីមួយៗនៃបញ្ញត្តិស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំនៃអ្នកជំនាញទាំងពីររូបនេះ គឺ 2-TCE-81 និង 2-TCE-82៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ | **លោក ពេជ អង្គ**<br>សហមេធាវីនាំមុខតំណាងដើម<br>បណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ | **លោកស្រី** Marie GUIRAUD<br>សហមេធាវីនាំមុខតំណាងដើម<br>បណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |